# ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យា៉

## ការិយាល័យអគ្គនាយកក្រសួងអប់រំ

**440 NORTH BROAD STREET, SUITE 301**
**PHILADELPHIA, PENNSYLVANIA 19130**

ការិយាល័យប្រតិបត្តិ

**ទូរស័ព្ទ៖ (២១៥) ៤០០-៤១០០**
**ទូរសារ៖ (២១៥) ៤០០-៤១០៤**

ថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៣

ជូនចំពោះ មាតាបិតា និងអាណាព្យាបាល៖

ក្រសួងអប់រំបានឈានដល់ដំណាក់កាលដ៏សំខាន់បំផុត ក្នុងឆ្នាំសិក្សារបស់យើង នេះជាពេលដែលការមករៀនទៀងទាត់របស់សិស្សជាការសំខាន់។ វាជាការលំបាកសម្រាប់សាលា ដើម្បីរក្សាស្ថិរភាពនៃចំនួនសិស្សដែលចុះឈ្មោះរៀន និងរៀបចំសិស្សានុសិស្សសម្រាប់ការប្រឡងទូទៅ បើសិនជាសិស្សានុសិស្សផ្លាស់ប្តូរពីសាលាមួយទៅសាលាមួយទៀត ញឹកញាប់យ៉ាងនេះ។ ត្រង់ចំណុចនេះ យើងខ្ញុំសូម ជំនួយ និងការសហការ ពីលោកអ្នក ដើម្បីផ្អាកសកម្មភាពនៃការផ្លាស់ប្តូរសាលារបស់សិស្ស ក្នុងចំណោមសាលារបស់ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យា៉ ដែលបានអនុវត្តក្នុងពេលថ្មីៗនេះ។ <u>នេះមានន័យថា សូមកុំផ្លាស់ប្តូរសិស្សពីសាលារបស់ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យា៉ មួយ ទៅសាលាមួយទៀត ចាប់ពី ថ្ងៃទី១១ ខែមីនា ដល់ ថ្ងៃទី៣ ខែឧសភា សម្រាប់សាលាបឋមសិក្សា និងអនុវិទ្យាល័យ និងពីថ្ងៃទី១១ ខែមីនា ដល់ថ្ងៃទី២៤ ខែឧសភា សម្រាប់វិទ្យាល័យ។</u> គេនឹងពិចារណាមើលតែការផ្លាស់ប្តូរសាលាណា ដែលមានលក្ខណៈចាំបាច់ តែប៉ុណ្ណោះ ហើយគេនឹងពិចារណាទៅតាមស្ថានភាពរបស់សិស្សម្នាក់ៗ។

សហគមន៍សាលាបានចាប់ផ្តើមឲ្យសិស្សធ្វើការប្រឡងទូទៅតាមការតម្រូវរបស់រដ្ឋ ដែលគេហៅថា PSSAs (ប្រព័ន្ធវាយតម្លៃសាលារបស់រដ្ឋផិនស៊ីលវេញ៉ា/ Pennsylvania System of School Assessment) សម្រាប់ថ្នាក់ទី៣ ដល់ថ្នាក់ទី៨។ បន្ទាប់ពីការប្រឡង PSSAs រួច សិស្សានុសិស្សវិទ្យាល័យ នឹងធ្វើការប្រឡង Keystone ដែលរដ្ឋតម្រូវឲ្យប្រឡង នៅពេលសិស្សរៀនចប់មុខវិជ្ជា ដែលគេបានរៀបចំឡើងដើម្បីវាយតម្លៃការស្ទាត់ជំនាញនៃមុខវិជ្ជាផ្សេងៗ។ ខាងក្រោមនេះគឺជាកាលវិភាគនៃថ្ងៃខែប្រឡងទាំងអស់។

| | | |
|---|---|---|
| ថ្ងៃទី ១១-១៥ ខែមីនា | ប្រឡង PSSA ការសរសេរ | ថ្នាក់ទី៥-ទី៨ |
| ថ្ងៃទី ១៨-២២ ខែមីនា | ប្រឡង PSSA ការសរសេរ សិស្សដែលមិនបានប្រឡងលើកមុន | ថ្នាក់ទី៥-ទី៨ |
| ថ្ងៃទី ៨-១៩ ខែមេសា | ប្រឡង PSSA គណិតវិទ្យា និងការអាន | ថ្នាក់ទី៣-ទី៨ |
| ថ្ងៃទី ២២-២៦ ខែមេសា | ប្រឡង PSSA ចំណេះវិទ្យាសាស្ត្រ | ថ្នាក់ទី៤-ទី៨ |
| ថ្ងៃទី២៩ ខែមេសា-ថ្ងៃទី៣ ខែឧសភា | ប្រឡង PSSA សិស្សដែលមិនបានប្រឡង គណិតវិទ្យា ការអាន និងចំណេះវិទ្យាសាស្ត្រ | ថ្នាក់ទី៣-ទី៨ |
| ថ្ងៃទី ១៣-២៤ ខែឧសភា | ប្រឡង Keystone ពិជគណិតកម្រិត I ជីវវិទ្យា និងអក្សរសិល្ប៍ | ថ្នាក់ទី៩-ទី១២ |

ការប្រឡងទាំងនេះសំខាន់ណាស់។ គេប្រើលទ្ធផលនៃការប្រឡងដើម្បីសម្រេចថា តើសិស្សានុសិស្សរៀនបានតាមកម្រិតថ្នាក់ប៉ុណ្ណា ផ្នែក គណិតវិទ្យា ការអាន ការសរសេរ និងចំណេះវិទ្យាសាស្ត្រ។ គេក៏ប្រើលទ្ធផលនៃការប្រឡង ដើម្បីធ្វើការសម្រេចចិត្តសំខាន់ៗ អំពីវិធានការនៃការអនុវត្តន៍ ដើម្បីកែលម្អជោគជ័យនៃការសិក្សានៅសាលារបស់សិស្ស។

សូមចាំទុកនៅក្នុងចិត្ត នូវការផ្អាកសកម្មភាពនៃការផ្លាស់ប្តូរសាលារបស់សិស្ស នៅពេលដែលលោកអ្នករៀបផែនការផ្ទាល់ខ្លួន និងសម្រាប់ក្រុមគ្រួសារ ដែលអាចជះឥទ្ធិពលដល់ ការចាត់តាំងឲ្យទៅសាលា ឬវត្តមានអវត្តមាននៅសាលា របស់កូនលោកអ្នក។ សូមអរគុណចំពោះការសហការជាមួយយើងខ្ញុំ ក្នុងខណៈដែលយើងរួមដៃគ្នាដើម្បីរៀបចំ និងចាត់ចែងការប្រឡងដ៏សំខាន់ សម្រាប់សិស្សានុសិស្សទាំងអស់។ បើសិនជាលោកអ្នកមានសំណួរអ្វី សូមទាក់ទងនាយកសាលារបស់លោកអ្នក។

ដោយសេចក្តីស្មោះស្ម័គ្រ



Karyn T. Lynch
នាយក ផ្នែកផ្តល់ជំនួយដល់សិស្ស

ចម្លងជូន៖ អគ្គនាយករង
　　　　នាយកសាលាទាំងអស់